Computer Lab Project of Pnhi Meas High School at Srok Prey Kabbas, Khet Takeo

## សេចក្តីរាយការណ៏ស្តីអំពីការវិវត្តន៏របស់កម្មវិធីបើកថ្នាក់បង្រៀនកុំព្យូទ័រ នៅសាលាវិទ្យាល័យភ្នីមាស ស្រុកព្រៃកប្បាស ខែត្រតាកែវ ថ្ងៃទី២៨ ខែ៩ ឆ្នាំ ២០០៦

សាលាវិទ្យាល័យភ្នីមាសមានកូនសិស្សសារុបទាំងអស់ជិត ២០០០នាក់គណៈកម្មាការសាលានេះនឹងឲ្យអាទិភាពដល់សិស្សថ្នាក់ទី១១ និងទី១២ បានចូលរៀនថ្នាក់កុំព្យូទ័រមុនគេ។ សាលារៀននេះនឹងបើកថ្នាក់បង្រៀនកុំព្យូទ័រជាលើកដំបូងនៅថ្ងៃទី២ ខែ១០ ឆ្នាំ២០០៦ នេះ ដែលជាថ្ងៃចូលរៀនដំបូងនៅក្នុងបវេស្សនៈកាលឆ្នាំ ២០០៦-២០០៧ នេះ។ សាលានេះនឹងមានបើក ១៤ថ្នាក់ ឬ១៤ក្រុមក្នុងមួយថ្នាក់ មានកូនសិស្សជាធម្យមប្រហែលជា ៤៥នាក់ ក្នុងមួយអាទិត្យបង្រៀន ២ម៉ោងក្នុងមួយថ្នាក់។ សិស្សដែលនឹងមកទទួលនូវចំណេះថ្មីនេះ មានចំនួនសារុបប្រហែលជា ៦៣០នាក់។

ជារៀងរាល់ថ្ងៃសៅរ៏និងថ្ងៃអាទិត្យយើងបានជួលគ្រូកុំព្យូទ័រពីភ្នំពេញ ឲ្យទៅបង្ហាត់ដល់លោកគ្រូអ្នកគ្រូចំនួន ២០នាក់នៅសាលារៀននេះផ្ទាល់តែម្តង ក្នុង១ថ្ងៃ ៦ម៉ោង (ក្នុង១អាទិត្យ ១២ម៉ោង) ចាប់តាំងតែពីខែ៧មកម្លេះ។ គ្រូដែលបានមកទទួលនូវការអប់រំផ្នែកវិជ្ជាកុំព្យូទ័រនេះមានចំនួន ២០នាក់។ មានតែគ្រូ ១០នាក់ទេ ដែលអាចចេញទៅបង្រៀនកូនសិស្សបាន។ គ្រូទាំងអស់នេះនឹងនៅតែទទួលការអប់រំវិជ្ជាខាងកុំព្យូទ័រនេះបន្ថែមតទៅទៀតឲ្យគ្រប់ចំនួន ១ឆ្នាំ ទើបបានអាចមានសមត្ថភាពគ្រប់គ្រាន់យកទៅបង្រៀនកូនសិស្សបានដោយប្រសិទ្ធិភាព។

សព្វថ្ងៃនេះសាលាបានទិញកុំព្យូទ័របានចំនួន ២៦គ្រឿងហើយ ហើយនឹងទិញបន្ថែមទៀត ព្រមទាំងរបស់របរចាំបាច់មួយចំនួនទៀត សំរាប់ឲ្យដំណើរការនេះដើរបាន។ សព្វថ្ងៃនេះម៉ាស៊ីនភ្លើងឯកជននៅផ្សារសែរ៉ាំបានបើកឲ្យប្រើនៅពេលថ្ងៃ តែគេនឹងឈប់បើកឲ្យប្រើនៅពេលខាងមុខនេះដោយមិនមានអតិថិជនណាផ្សេងទៀតក្រៅពីសាលាយើងនេះ និងដោយគេគ្មានកំរៃ។ គំរោងចំណាយក្នុងកម្មវិធីបើកបង្រៀនថ្នាក់កុំព្យូទ័រ នេះមានចំនួន ១៦០០០ដុល្លា ក្នុងរយៈពេលមួយឆ្នាំដំបូង។ ចំណាយដែលមានជំឡែច្រើនជាងគេគឺ :

១- ថ្លៃទិញកុំព្យូទ័រ ពី២៥ ទៅ៥០គ្រឿងបើសិនជាមានលទ្ធភាពធ្វើបាន

២- ថ្លៃជួលគ្រូមកពីភ្នំពេញ ឲ្យមកបង្រៀនអប់រំដល់លោកគ្រូអ្នកគ្រូនៅសាលានេះផ្ទាល់តែម្តងដើម្បីឲ្យគាត់មានចំណេះយកទៅបង្ហាត់កូនសិស្សរបស់គាត់។

៣-ថ្លៃភ្លើងអគ្គីសនី ឬថ្លៃទិញប្រេងសាំងឬប្រេងម៉ាស៊ូតចាក់ម៉ាស៊ីនភ្លើង។

៤-ក្រៅពីនោះយើងក៏ត្រូវការទិញម៉ាស៊ីន Printer/Scaner/Copier ២ ម៉ាស៊ីន Projector ១គ្រឿង ម៉ាស៊ីនភ្លើង Generator ១គ្រឿង ក្រដាសសំរាប់បោះពុម្ព ទឹកខ្មៅសំរាប់បោះពុម្ព Printing Ink ឬ Toner ជាដើម។

៥-របស់របរបន្ទាប់បន្សំជាច្រើនមុខទៀត រហូតមកទល់សព្វថ្ងៃនេះ យើងរៃលុយបានចំនួន ១២០០០ ដុល្លារួចហើយ។ យើងបានផ្ញើលុយទៅជាបន្តបន្ទាប់បានចំនួន ១១០០០ដុល្លារួចហើយ។ លុយទាំងអស់នោះ បានមកពីសប្បុសរជននៅសហរដ្ឋអាមេរិក កាណាដា ហើយក៏មានបងប្អូនយើងនៅក្នុងស្រុកខ្មែរមួយចំនួន ផងដែរ បានជួយឧបត្ថម្ភជាលុយកាក់ខ្លះ និងជាកុំព្យូទ័រខ្លះផងដែរ។ យើងនឹងធ្វើបញ្ជីឈ្មោះសប្បុសរជន ទាំងអស់ ព្រមទាំងការចំណូលចំណាយជាទូទៅជូនបងប្អូនយើងទុកមើលនៅពេលក្រោយនេះ។

នៅថ្ងៃទី១ ខែ១១ ឆ្នាំ២០០៦ ខាងមុខនេះ យើងនឹងទៅធ្វើពិធីប្រគល់នូវគ្រឿងបរិក្ខាកុំព្យូទ័រទាំងអស់នេះ ជូនដល់សាលារៀនភ្ជីមាសជាផ្លូវការ ដូច្នេះបើសិនជាមានបងប្អូនយើងណាអាចមានពេលទៅបាន សូមលៃលក ទុកពេលនេះទៅចូលរួមជាមួយយើងខ្ញុំផងកុំបីខានឲ្យសោះ។

ខ្ញុំសូមអំពាវនាវដល់បងប្អូនសប្បុសរជនទាំងអស់ មេត្តាចូលរួមជួយដល់កម្មវិធីបង្រៀនកុំព្យូទ័រយើងនេះ ឲ្យបានតាមគោលដៅខាងលើរបស់យើងនេះផងកុំបីអាក់ខានឲ្យសោះ។

សូមមេត្តាសរសេរសែកផ្ញើមកឲ្យយើងខ្ញុំ តាមអាស័យដ្ឋានដូចមានខាងក្រោមនេះ។ អំណោយរបស់លោក អ្នកនៅពេលនេះ អាចយកទៅដកនៅពេលធ្វើតាក់ដាច់ឆ្នាំនេះបាន :

Please make your check pay to :

Khmer Alliance Foundation or Pay to : K. A. F.
Mailing Address : Chip Tan
15211 – SE First St.
Bellevue, WA. 98007

Any question please contact Mr. Chip Tan at (206)778-3328
Note : Your donation is tax deductible because we are a Non-Profit Organization

សូមអរគុណទុកជាមុន
អំពីខ្ញុំតាន់-ជាប
ប្រធានគណៈកម្មការគាំទ្រកម្មវិធីបើកថ្នាក់បង្រៀន
កុំព្យូទ័រនៅសាលាវិទ្យាល័យភ្ជីមាស ស្រុកព្រៃកប្បាស ខេត្រតាកែវ